រស្មីកម្ពុជា ផ្នែកខ ប្រចាំថ្ងៃ
RASMEI KAMPUCHEA DAILY
ឆ្នាំទី 19 លេខ 5423 ថ្ងៃ អាទិត្យ-ចន្ទ ទី 06-07 ខែ កុម្ភៈ ឆ្នាំ 2011

# ១០០ឆ្នាំក្រោយមកទើបផ្សាយឡើងវិញសៀវភៅរបស់ស្ថាបនិកសារមន្ទីរជាតិ

**ភ្នំពេញ :** ចង្កៀងធ្វើពីដីដែលមានដាក់ទៀនបានដុតបំភ្លឺ និងអំពូលភ្លើងក្នុងបរិវេណសារមន្ទីរជាតិក្រុងភ្នំពេញ ត្រូវបានបើកបំភ្លឺក្នុងពេលរាត្រីលើកដំបូង ដើម្បីឧទ្ទិសដល់លោក ចចស៍ ហ្ក្រោសរីយេ ដែលជាស្ថាបនិកសារមន្ទីរនេះ និងសាលារចនា ដែលបច្ចុប្បន្នប្រែក្លាយជាសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈរបស់ប្រទេសនេះ ។

លោកចចស៍ ហ្ក្រោសលីយេ ជាជនជាតិបារាំង និងជាជនបញ្ញាមប្រទេស

តទៅទំព័រ ខ6



ក្រុមអ្នករបាំមកពីសាលាមូលនិធិធិនការវិត ដើម្បីកម្ពុជា ចូលរួមពិធី (រូបៈលាងហួរ)

តមកពីទំព័រ ខ1

# ១០០ឆ្នាំក្រោយមក...



សម្តេចព្រះរាមនរោត្តមបុប្ផា ទេវី អុជធូបបួងសួង ដល់វិញ្ញាណក្ខន្ធលោកចចស៍ ហ្គ្រោសលីយេ (រូបថត:ល្បេងហួរ)




សៀវភៅដែលបានបោះពុម្ពផ្សាយបច្ចុប្បន្ននេះ

ដំបូងគេ ដែលបានកើតរស់នៅ និងស្លាប់នៅប្រទេសកម្ពុជា ហើយលោកក៏ជាអ្នកស្រឡាញ់ប្រជាជនខ្មែរម្នាក់យ៉ាងជ្រាលជ្រៅ ដោយលោកបានបន្សល់នូវសំណង់សារមន្ទីរជាតិដ៏ល្អឯកបន្សល់នូវអគារសាកលវិទ្យាល័យភូមិន្ទវិចិត្រ-សិល្បៈ និងសៀវភៅជាច្រើនដែលនិយាយអំពីប្រវត្តិសាស្ត្រ វប្បធម៌របស់ប្រទេសកម្ពុជា ប្រមាណ១០០ចំណងជើង ហើយរាត្រីថ្ងៃសុក្រទី៤ កុម្ភៈកន្លងមកនេះ សៀវភៅមានចំណងជើងថា **អ្នករបាំកម្ពុជាបុរាណនិងសម័យ** ត្រូវបានបង្ហាញខ្លួនជាថ្មីក្នុងការបោះពុម្ពលើកទី២បន្ទាប់ពីរយៈពេល១០០ឆ្នាំ នៃការបោះពុម្ពលើកទី១ ចំថ្ងៃរំលឹកខួបកំណើតរបស់លោកលើកទី១២៤ឆ្នាំ ។

ពិធីនេះបានទាក់ទាញឯកអគ្គរដ្ឋទូតបារាំង ឯកអគ្គរាជទូតអង់គ្លេស ភារៈធារីសហគមន៍អឺរ៉ុប ប្រចាំកម្ពុជា សម្តេចព្រះរាមនរោត្តម បុប្ផាទេវី យាងចូលរួម និងមន្ត្រីជាន់ខ្ពស់ជាច្រើនទៀត បានចូលរួម ដើម្បីរំលឹកដល់វិញ្ញាណក្ខន្ធលោកចចស៍ ហ្គ្រោសលីយេ និងមើលកេរ-ដំណែលរបស់លោកដែលបានធ្វើ ដើម្បីប្រជាជនខ្មែរ ។

លោកស្រីកន្ទាវ៉ាវីន ងិនការ៉េត ប្រធានមូលនិធិងិនការេតសម្រាប់កម្ពុជា ដែលដើរតួនាទីយ៉ាងសំខាន់សម្រាប់ការប្រារព្ធពិធីឧទ្ទិសដល់វិញ្ញាណក្ខន្ធលោកចចស៍ ហ្គ្រោសរីយេ និងជួយរៀបចំឱ្យមានការបោះពុម្ពសៀវភៅនេះជាលើកទី២ បានមានប្រសាសន៍ឱ្យដឹងក្នុងពិធីនោះថា ការប្រារពពិធីនេះ ដើម្បីអញ្ជើញវិញ្ញាណក្ខន្ធលោកចចស៍ ហ្គ្រោ-សរីយេ មកថែរក្សានិងស្ថិតនៅថែរក្សាកេរដំណែលរបស់លោក គឺសារមន្ទីរជាតិក្រុងភ្នំពេញនេះ ដែលលោកបានគូប្លង់និងជាស្ថាបនិកនូវបេតិកភណ្ឌដ៏ល្អវិចិត្រនេះ ។

នារាត្រីនោះក៏បានចេញផ្សាយសៀវភៅមួយក្នុងចំណោមសៀវភៅជាច្រើនរបស់លោកចចស៍ ហ្គ្រោសលីយេ ដែលមានចំនួន៤៦៦ទំព័រ ដែលសរ-សេរជាភាសាអង់គ្លេស និងភាសាបារាំង និងមានពន្យល់ជារូបថត និងរូបគូរដោយលោកជាច្រើនផងដែរ ។

លោកស្រីបានបន្តថា "លោកហ្គ្រោសលីយេ បានបូជាជីវិតរបស់លោកដើម្បីកម្ពុជាលោកមិនចាកចេញពី-កម្ពុជានោះទេ លោកបានកើតនៅកម្ពុជាកសាងសមិទ្ធផលជាច្រើន ដើម្បីកម្ពុជានិងស្លាប់នៅកម្ពុជា" ។ លោកស្រីបន្តថា "នៅពេលកងទ័ពបារាំងចាញ់កងទ័ពជប៉ុនក្នុងសង្គ្រាមលោកលើកទី២ជន-ជាតិបារាំងទាំងអស់ បានចាកចេញពីប្រទេសកម្ពុជា ប៉ុន្តែលោកចចស៍ ហ្គ្រោ-លីយេមិនចាកចេញពីកម្ពុជាទេ លោកនៅកម្ពុជារហូតត្រូវកងទ័ពជប៉ុនធ្វើទារុណកម្មរហូតដល់បាត់បង់ជីវិត" ។

លោកស្រីកន្ទាវាវិន ងិនការ៉េត បានមានប្រសាសន៍ថា សៀវភៅនិយាយអំពីអ្នករបាំកម្ពុជា បុរាណ និងសម័យ បោះពុម្ពលើកទី២ចំនួន១.០០០ច្បាប់ ដែលមានដាក់លក់នៅMonument Book ហើយលោកស្រីនឹងត្រៀមបោះ-ពុម្ពដោយបកប្រែជាភាសាខ្មែរក្នុងអំឡុងដំណាច់ឆ្នាំនេះ ។

លោកខេន ដាវីស KENT DAVIS ដែលបានធ្វើការសហការជាមួយកូនស្រីលោកចចស៍ ហ្គ្រោសលីយេ ដើម្បីរៀបចំសៀវភៅនេះអស់រយៈពេលបីឆ្នាំ បានមានប្រសាសន៍ថា សៀវភៅនេះបានបង្ហាញឱ្យឃើញគោលសំខាន់ៗជាច្រើន ដែលនេះជាការបោះពុម្ពឡើងវិញលើកដំបូងនៃសៀវភៅ Danseuses Cambodgiennes ជាភាសាដទៃចាប់តាំងពីឆ្នាំ១៩១៣មកហើយ នេះក៏ជាការបកប្រែលើកដំបូងបំផុតនៃរាល់ស្នាដៃរបស់លោកហ្គ្រោស លីយេ ជាភាសា-អង់គ្លេស ។

លោកបន្តថា "អ្វីដែលសំខាន់និងជ្រាលជ្រៅនោះ គឺស្នាដៃនេះត្រូវបានបង្កើតឡើងដោយលោកហ្គ្រោស លីយេរយៈពេលមួយសតវត្សរ៍ ដែលការពិតត្រូវបានបោះពុម្ពនៅក្នុងប្រទេសកម្ពុជាដោយប្រជាជនកម្ពុជា" ។

លោកឯកអគ្គរដ្ឋទូតបារាំងប្រចាំកម្ពុជាគ្រីស្ទាន កូនេន Christian Connana បានមើលឃើញពីសារៈ-សំខាន់នៃស្នាដៃរបស់លោកចចស៍-ហ្គ្រោសលីយេកាន់តែមានសារសំខាន់ទៅទៀតដោយលោកបានមានប្រសាសន៍ថា ការបោះពុម្ពសៀវភៅរបស់លោកចចស៍ ហ្គ្រោសលីយេ ឡើងវិញនេះស្ថានទូតសូមសម្តែងការគោរពដល់អ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ដ៏ឆ្នើមរូបនេះ ដែលសៀវភៅរបស់គាត់ជាគំរូនៃចំណងមិត្តភាពរវាងប្រទេសបារាំង-កម្ពុជា ។

លោកចចស៍ ហ្គ្រោសលីយេ មានកូនស្រីម្នាក់ ដែលបានកើតនៅប្រទេសកម្ពុជា និងបច្ចុប្បន្នរស់នៅសហរដ្ឋអាមេរិកឈ្មោះនីកូល ហ្គ្រោស-លីយេ បាននិយាយថា "ខ្ញុំតែងស្រឡាញ់ប្រទេសកម្ពុជាយ៉ាងជ្រាលជ្រៅក្នុងបេះដូងខ្ញុំឪពុករបស់ខ្ញុំបានបូជាជីវិតរបស់គាត់ ដើម្បីសិល្បៈរបស់ខ្មែរហើយបានបណ្តាលឱ្យខ្ញុំជ្រួតជ្រាបថា ក្តីស្រឡាញ់និងចំណេះដឹងរបស់គាត់នឹងមានបន្តទៅដល់កូនចៅខ្មែរជំនាន់ក្រោយៗ-ទៀត" ៕ **ប្រាយ ចំណាន**